LI & FUNG

# ក្រមសីលធម៌របស់អ្នកផ្គត់ផ្គង់

សកម្មភាព (Li & Fung) របស់ក្រុមហ៊ុន Li & Fung (Trading) Ltd. តាងនាមឲ្យអតិថិជនរបស់ខ្លួន អាស្រ័យលើប្រភពពីអ្នកផ្គត់ផ្គង់នានា នៅជុំវិញពិភពលោក។ យើងធ្វើការជាមួយនឹងខ្សែសង្វាក់ផ្គត់ផ្គង់សកលរបស់យើង ដើម្បីបង្កើតលក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព ដើម្បីលើកកម្ពស់ភាពថ្លៃថ្នូរ និងការគោរពចំពោះបុគ្គលិក និងដើម្បីជំរុញទម្លាប់អនុវត្តន៍ក្នុងបរិយាកាសប្រកបដោយទំនួលខុសត្រូវ។

ក្រមសីលធម៌អ្នកផ្គត់ផ្គង់របស់យើង និងស្តង់ដារដែលអមមកជាមួយ រៀបរាប់លម្អិតអំពីគោលការណ៍ និងទម្លាប់អនុវត្តន៍នានា ដែលយើងរំពឹងចង់ឲ្យអ្នកផ្គត់ផ្គង់របស់យើងគោរពតាម។ ក្រមនេះ ដោយផ្អែកលើច្បាប់/បទប្បញ្ញត្តិក្នុងស្រុក ថ្នាក់ជាតិ អនុសញ្ញាសំខាន់ៗរបស់អង្គការពលកម្មអន្តរជាតិ (ILO) និងស្តង់ដារសុខភាព សុវត្ថិភាព និងបរិយាកាសការងារដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ តំណាងឲ្យការប្តេជ្ញាចិត្តរបស់យើងក្នុងការយកទំនិញពីអ្នកផ្គត់ផ្គង់ ដែលផ្តល់តម្លៃ និងរួមបញ្ចូលបញ្ញត្តិទាំងនេះទៅក្នុងប្រតិបត្តិការរបស់ពួកគេ។

ទោះបីជានិយោជិតរបស់អ្នកផ្គត់ផ្គង់នៅក្នុងផ្នែកផ្សេងៗ មានប្រភេទការងារផ្សេងៗគ្នាក៏ដោយ ក្រមប្រតិបត្តិរបស់អ្នកផ្គត់ផ្គង់អាចអនុវត្តបានចំពោះរាល់ទីតាំងការងារទាំងអស់ដែលត្រូវបានប្រើប្រាស់សម្រាប់ប្រភព Li & Fung និងហេដ្ឋារចនាសម្ព័ន្ធស្នាក់នៅ នៅទីតាំងដែលពាក់ព័ន្ធនានា។

## ប្រព័ន្ធគ្រប់គ្រង

- ថ្នាក់គ្រប់គ្រងអ្នកផ្គត់ផ្គង់ បង្កើតគោលនយោបាយ និងប្រព័ន្ធនានាដើម្បីគ្រប់គ្រងហានិភ័យ និងបណ្តឹងសារទុក្ខ។

## ទម្លាប់អនុវត្តន៍ផ្នែកសុខភាព និងសុវត្ថិភាព

- អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងលិខិតបញ្ជាក់នានា មានលក្ខណៈត្រឹមត្រូវ ពេញលេញ និងមានបច្ចុប្បន្នភាព តាមការតម្រូវនៃច្បាប់។ រាល់លិខិតជូនដំណឹងទាំងអស់ បំពេញតាម ឬលើសពីបទប្បញ្ញត្តិច្បាប់។
- បុគ្គលិកសមស្រប មានទំនួលខុសត្រូវចំពោះការឆ្លើយតបក្នុងគ្រាអាសន្ន សុខភាព និងសុវត្ថិភាព។
- អ្នកផ្គត់ផ្គង់អនុវត្ត និងរក្សាការប្រុងប្រយ័ត្នចំពោះគ្រាអាសន្ន និងសុវត្ថិភាព ដែលបំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- អ្នកផ្គត់ផ្គង់ ផ្តល់ជំនួយសង្គ្រោះបឋម និងការថែទាំវេជ្ជសាស្ត្រ ដែលបំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- អ្នកផ្គត់ផ្គង់រាយការណ៍ ស៊ើបអង្កេត និងដោះស្រាយបញ្ហាគ្រោះថ្នាក់របស់និយោជិត និងនៅទីតាំង ក្នុងលក្ខណៈមួយដែលបំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- គោលនយោបាយ ការបណ្តុះបណ្តាល ការផ្តល់ ការថែរក្សា និងការប្រើប្រាស់ឧបករណ៍ការពារផ្ទាល់ខ្លួន បំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- មានគោលនយោបាយ និងការបណ្តុះបណ្តាលអំពីការរក្សាទុកនៅក្នុងទីធ្លាដែលមានដែនកំណត់ នៅលើដី និងនៅក្រោមដី (AST & UST)។
- ការគ្រប់គ្រង គោលនយោបាយ ការបណ្តុះបណ្តាល ការថែទាំ ការរក្សាទុក និងការប្រើប្រាស់សារធាតុគីមី និងសម្ភារគ្រោះថ្នាក់ បំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- ការជក់បារី និងសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងអណ្តាតភ្លើង ភ្លើង ឬការបញ្ឆេះភ្លើងដោយបើកចំហ ត្រូវបានហាមឃាត់នៅកន្លែងដែលបានកំណត់។
- ការគ្រប់គ្រង គោលនយោបាយ ការបណ្តុះបណ្តាល និងការថែរក្សាសុវត្ថិភាពឧបករណ៍ បំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- សមាសធាតុ និងប្រព័ន្ធអគ្គិសនី ត្រូវបានថែទាំយ៉ាងត្រឹមត្រូវ។
- កម្រិតសំឡេងរំខានត្រូវបានគ្រប់គ្រង ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- អ្នកផ្គត់ផ្គង់ថែរក្សាកន្លែងធ្វើការងារមួយដែលមានពន្លឺ ខ្យល់ចេញចូល និងសីតុណ្ហភាពដែលត្រូវបានគ្រប់គ្រងក្នុងលក្ខណៈមួយដែលបំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- អ្នកផ្គត់ផ្គង់ថែរក្សាមជ្ឈដ្ឋានការងារមួយដែលស្អាត និងផ្តល់ទឹកសម្រាប់ពិសា បន្ទប់ទឹក និងកន្លែងងូតទឹក ក្នុងលក្ខណៈមួយដែលបំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។

- កន្លែងរៀបចំអាហារ និងកន្លែងថៃទាំកុមារ បំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- លិខិតអនុញ្ញាតការសាងសង់ និងសំណង់ ត្រូវបានថែរក្សាទុក និងមានភាពត្រឹមត្រូវ។
- អ្នកផ្គត់ផ្គង់អនុវត្តកម្មវិធីហានិភ័យផ្នែកផាសុកភាពវិទ្យា និងផ្តល់ការបណ្តុះបណ្តាលដើម្បីឲ្យមានការយល់ដឹងអំពីផាសុកភាពវិទ្យា។
- ស្ថានភាពអន្តេវាសិកដ្ឋាន និងការប្រុងប្រយ័ត្នចំពោះហេតុការណ៍គ្រាអាសន្ន និងសុវត្ថិភាព បំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។

## ទម្លាប់អនុវត្តន៍ផ្នែកពលកម្ម

- អាជ្ញាប័ណ្ណអាជីវកម្ម មានភាពត្រឹមត្រូវ មានសុពលភាព និងមានបច្ចុប្បន្នភាព តាមការតម្រូវនៃច្បាប់។ រាល់ការបិទផ្សាយទាំងអស់ បំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- រាល់ទម្លាប់អនុវត្តន៍ក្នុងការជួលបុគ្គលិក និងបញ្ចប់ការងារទាំងអស់ បំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។ អ្នកផ្គត់ផ្គង់ប្រកាន់យកទម្លាប់អនុវត្តន៍ក្នុងការជ្រើសរើសបុគ្គលិកយ៉ាងហ្មត់ចត់ ដើម្បីកាត់បន្ថយហានិភ័យនៃការជួញដូរមនុស្ស។
- ការរក្សាកំណត់ត្រាប្រាក់ឈ្នួល និងបញ្ជីប្រាក់បៀវត្សរ៍របស់និយោជិត បំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- អត្ថប្រយោជន៍របស់និយោជិត បំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- ម៉ោងធ្វើការ និងកំណត់ត្រាម៉ោងធ្វើការរបស់និយោជិត បំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- ពលកម្មដោយបង្ខំ ជាប់ចំណង ជាប់បំណុល ទាសភាព និងជាប់ឃុំឃាំង ត្រូវបានហាមឃាត់។
- ការងាររបស់យុវជនដែលអាយុមិនតិចជាង ១៥ឆ្នាំ អ្នកហាត់ការ និងសិក្ខាកាម បំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- ការរំលោភបំពាន ការបង្ខិតបង្ខំ ការបៀតបៀន និងវិធានការវិន័យមិនសមស្របនានា ត្រូវបានហាមឃាត់។
- ទម្លាប់អនុវត្តន៍ដែលមានភាពរើសអើង ត្រូវបានហាមឃាត់។
- ត្រូវតែគោរពសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងការចរចាជាសមូហភាព។

LI & FUNG

## ទម្លាប់អនុវត្តន៍ផ្នែកបរិស្ថាន

- ការគ្រប់គ្រង គោលនយោបាយ និងការបិទផ្សាយព័ត៌មានផ្នែកបរិស្ថាន បំពេញតាម ឬលើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់។
- អ្នកផ្គត់ផ្គង់ត្រូវកាត់បន្ថយផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថាន កាត់បន្ថយកាកសំណល់ និងទប់ស្កាត់ការបំពុល។

## គណនេយ្យភាព តម្លាភាព និងសីលធម៌

- អ្នកផ្គត់ផ្គង់ផ្តល់សិទ្ធិចេញចូលទីតាំងដោយគ្មានឧបសគ្គ ដើម្បីផ្ទៀងផ្ទាត់អនុលោមភាព និងការប្តេជ្ញាចិត្តក្នុងការកែលម្អបដិលោមភាពដែលបានសម្គាល់ឃើញ។
- ចាំបាច់ត្រូវលាតត្រដាងឲ្យដឹង នូវរាល់សកម្មភាពចុះកិច្ចសន្យាបន្ត និងកិច្ចការធ្វើនៅផ្ទះទាំងអស់ ហើយរោងចក្រត្រូវតែថែរក្សាការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី Li & Fung និង/ឬអតិថិជនរបស់ខ្លួន។
- ការបោកបន្លំ ការសូកប៉ាន់ និងការជះឥទ្ធិពលមិនសមស្របរបស់និយោជិត Li & Fung ឬតំណាងដែលត្រូវបានចាត់តាំងរបស់ Li & Fung ត្រូវបានហាមឃាត់។